**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រ.ក/លេខ ០៥.០៦២/១៤ គ.ជ.ប/អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៤

# ការទទួលស្គាល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២

គិតត្រឹមថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតបានទទួលស្គាល់តំណាងគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោត សរុបចំនួន 843នាក់ ក្នុងនោះតំណាងពេញសិទ្ធិមានចំនួន 424នាក់(ស្ត្រី 43នាក់) និងតំណាងបម្រុង ចំនួន 419នាក់(ស្ត្រី 53នាក់) ។ តំណាងគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោតទាំងនេះមកពីគណបក្ស ចំនួន 5 ៖

- គណបក្សប្រជាជនកម្ពុជា (ពេញសិទ្ធិ 198នាក់ និងបម្រុង 198នាក់)
- គណបក្សសង្គ្រោះជាតិ (ពេញសិទ្ធិ 195នាក់ និងបម្រុង 196នាក់)
- គណបក្សហ៊្វុនស៊ិនប៉ិច (ពេញសិទ្ធិ 26នាក់ និងបម្រុង 23នាក់)
- គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ (ពេញសិទ្ធិ 2នាក់ និងបម្រុង 2នាក់)
- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (ពេញសិទ្ធិ 3នាក់) ។

រីឯការទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិ គិតត្រឹមថ្ងៃនេះដែរ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍សរុបចំនួន 159នាក់ ក្នុងនោះអ្នកសង្កេតការណ៍ចល័តចំនួន 10នាក់ ។ អ្នកសង្កេតការណ៍ទាំងនេះមកពីអង្គការមិនមែនរដ្ឋាភិបាលចំនួន 4 ៖

- អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ (សរុបចំនួន 27នាក់ ក្នុងនោះចល័ត 5នាក់)
- អង្គការសហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (សរុបចំនួន 26នាក់)
- អង្គការសហព័ន្ធនិស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា (សរុបចំនួន 54នាក់ ក្នុងនោះចល័ត 5នាក់)
- អង្គការទប់ស្កាត់បទល្មើសនៅកម្ពុជា (សរុបចំនួន 52នាក់) ៕